**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០០៣៥ រ៉ែ.ឋប្រក

ថ្ងៃសុក្រ ១១រោចខែស្រាពណ៍ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មានពាក់ព័ន្ធនឹង
# នាវាដឹកប្រេង MT Strovolos និង ប្រេងឆៅរបស់ព្រះរាជាណាចក្រកម្ពុជា

**ក្រសួងរ៉ែ និងថាមពល** សូមធ្វើសេចក្តីប្រកាសព័ត៌មានពាក់ព័ន្ធនឹងនាវា MT Strovolos និង ប្រេងឆៅប្រហែល ៣០ ម៉ឺន បារ៉ែល របស់ព្រះរាជាណាចក្រកម្ពុជា៖

គោលបំណងនៃសេចក្តីប្រកាសពត៌មាននេះ គឺដើម្បីធ្វើការបញ្ជាក់ដូចខាងក្រោម៖

- ទំនិញជាប្រេងឆៅ នៅលើនាវា MT Strovolos គឺជាប្រេងឆៅរបស់ព្រះរាជាណាចក្រកម្ពុជា ។
- វិវាទពាក់ព័ន្ធនឹងថ្លៃឈ្នួលនាវា គឺជាវិវាទរវាងម្ចាស់ ឬ អ្នកគ្រប់គ្រងនាវា និង អ្នកជួលនាវា ហើយវិវាទនេះមិនពាក់ព័ន្ធនឹងព្រះរាជាណាចក្រកម្ពុជា ឡើយ។
- នាវា MT Strovolos បានចាកចេញពីដែនទឹកកម្ពុជាដោយខុសច្បាប់ និង ដោយសម្ងាត់ ហើយនាវានេះបានបន្តធ្វើដំណើររហូតដល់ដែនទឹកនៃប្រទេសឥណ្ឌូណេស៊ី ដែលជាកន្លែងដែលនាវានោះត្រូវបានឃាត់ទុក និង
- សកម្មភាពទាំងឡាយរបស់នាវា MT Strovolos បានរំលោភច្បាប់ប្រទេសកម្ពុជា និង ប្រទេសឥណ្ឌូណេស៊ី ហើយបច្ចុប្បន្ន អ្នកពាក់ព័ន្ធកំពុងតែត្រូវបានស៊ើបអង្កេតដោយតុលាការមានសមត្ថកិច្ច។

## អំពីដំណើររឿង

សូមបញ្ជាក់ថា ក្រុមហ៊ុន World Tankers Management Pte Ltd គឺជាអ្នកគ្រប់គ្រងនាវា MT Strovolos ដែលត្រូវបានជួលដោយក្រុមហ៊ុនមួយ នៃគ្រីសអេនើជីគ្រុប (KrisEnergy Group) ដើម្បីធ្វើជានាវាស្តុកទុក និង ផ្ទេរ (Floating Storage and Offloading) ប្រេងឆៅពីតំបន់អប្បរាប្លុក A ក្នុងដែនសមុទ្រកម្ពុជា (តំបន់ប្លុក A កម្ពុជា)។

នាវា MT Strovolos ត្រូវបានជួលដោយ **ក្រុមហ៊ុន គ្រីសអេនើជី** ដើម្បីផ្តល់សេវាខាងលើ ដែលក្រុមហ៊ុននេះមានកិច្ចសន្យាជាមួយ **រាជរដ្ឋាភិបាលកម្ពុជា** ដែលតំណាងដោយ **ក្រសួងរ៉ែ និងថាមពល** សម្រាប់ការស្វែងរុករក និង អភិវឌ្ឍក្នុងតំបន់អប្បរា ប្លុកA កម្ពុជា។



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

## ការយកប្រេងនៅចេញពីដែនទឹកកម្ពុជា

នាវា MT Strovolos បានចត និង ភ្ជាប់ទៅនឹងនាវាផលិតកម្មប្រេង ដើម្បីទទួល ស្តុក និង ផ្ទេរប្រេងទៅនាវាផ្សេងទៀត ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតរបស់កម្ពុជា។ ក្រសួងរ៉ែនិងថាមពល ដឹងថាបច្ចុប្បន្នម្ចាស់ ឬ អ្នកគ្រប់គ្រងនាវា និង អ្នកជួលនាវា ក្រុមហ៊ុន គ្រីសអេនើជី កំពុងតែមានវិវាទពាក់ព័ន្ធនឹងការបង់ថ្លៃឈ្នួលនាវា។ ប្រសិនព័ត៌មាននេះជាការពិត វិវាទនេះ គឺជាវិវាទរបស់ភាគីទាំងពីរ ហើយមិនជាប់ពាក់ព័ន្ធនឹងព្រះរាជាណាចក្រកម្ពុជា និង ប្រេងនៅរបស់កម្ពុជាឡើយ។

ក្នុងអំឡុងពេលជួលនាវាឲ្យទៅ ក្រុមហ៊ុនគ្រីសអេនើជី នាវា MT Strovolos ត្រូវបានបញ្ជាដោយក្រុមហ៊ុន World Tankers Management Pte Ltd នៅល្ងាចថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០២១ ឲ្យចាកចេញពីកម្ពុជានៅម៉ោង ៨:00 ល្ងាច ទៅកាន់ដែនទឹកប្រទេសថៃឡង់ដ៏ ដោយយកប្រេងនៅរបស់កម្ពុជាទៅជាមួយផងដែរ។ ការចាកចេញរបស់នាវា MT Strovolos ធ្វើឡើងដោយមិនបានឆ្លងកាត់នីតិវិធីប្រតិវេទន៍គយ និងដោយគ្មានការអនុញ្ញាតណាមួយពីសំណាក់អាជ្ញាធរកម្ពុជាឡើយ ដែលផ្ទុយនឹងច្បាប់កម្ពុជា។

ប្រព័ន្ធកំណត់ទីតាំងស្វ័យប្រវត្តិ (Automatic Identification System) របស់នាវានេះ ត្រូវបានបិទនៅម៉ោង ១២:២៣ ព្រឹកថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០២១ ដែលនាំឲ្យការកំណត់ទីតាំងនាវានេះ មិនអាចធ្វើទៅបាន ។ ប្រព័ន្ធស្វ័យប្រវត្តិនេះ ត្រូវបានដាក់ឲ្យដំណើរការឡើងវិញនៅម៉ោង ១០:៤៨ នាទីយប់ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០២១ ជិតពីរថ្ងៃ ក្រោយពេលដែលនាវានេះបានចេញផុតពីដែនសមុទ្រកម្ពុជា ។ ប្រព័ន្ធ AIS បានបិទជាបន្តបន្ទាប់ក្នុងពេលដែលនាវានេះ បានធ្វើដំណើរទៅកាន់ដែនទឹកឥណ្ឌូណេស៊ី។

**ក្រសួងរ៉ែនិងថាមពល** សូមច្រានចោលការលើកឡើងរបស់ក្រុមហ៊ុន World Tankers Management Pte Ltd នៅក្នុងសេចក្តីប្រកាសពត៌មានរបស់ខ្លួនដែលថា នាវា MT Strovolos គ្មានជម្រើសផ្សេងក្រៅពីចាកចេញពីប្រទេសកម្ពុជា ដើម្បីធ្វើការផ្លាស់ប្តូរនាវិក និង ចាក់ប្រេង។ ក្រសួងរ៉ែនិងថាមពល ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាផ្សេងទៀត មិនដែលបានទទួលដំណឹងពីម្ចាស់នាវា អ្នកគ្រប់គ្រងនាវា ឬ ភាគីណាមួយ ស្នើសុំឲ្យរៀបចំ ឬ អនុញ្ញាតឲ្យធ្វើការផ្លាស់ប្តូរនាវិក និង ចាក់ប្រេងនាវានេះឡើយ។ ទោះបីយ៉ាងណាក៏ដោយ ក៏បញ្ហានៃការប្តូរនាវិក ឬ ការចាក់ប្រេងនេះ មិនអាចយកមកធ្វើជាលេសដើម្បីឲ្យនាវា MT Strovolos ចាកចេញ និង យកប្រេងឆៅកម្ពុជាទៅជាមួយ ដោយមិនអនុលោមតាមច្បាប់កម្ពុជាឡើយ។ ក្រោយពេលដែលនាវា MT Strovolos បានចាកចេញពីដែនទឹកកម្ពុជាដោយខុសច្បាប់ នាវានេះ មិនដែលបានបង្ហាញឆន្ទៈក្នុងការវិលត្រឡប់ ឬ ដឹកប្រេងឆៅមកដែនទឹកកម្ពុជាវិញឡើយ បើទោះបីជាម្ចាស់នាវា អ្នកគ្រប់គ្រង ប្រធានក្រុម និង នាវិកនៅលើនាវានេះ បានដឹងយ៉ាងច្បាស់ថាប្រេងឆៅនៅលើនាវារបស់ខ្លួន គឺជាទ្រព្យសម្បត្តិរបស់ព្រះរាជាណាចក្រកម្ពុជា។

## បច្ចុប្បន្នភាពនៃបញ្ហា

**ក្រសួងរ៉ែនិងថាមពល** បានដឹងថានាវា MT Strovolos ត្រូវបានឃាត់ទុកនៅសាធារណរដ្ឋឥណ្ឌូណេស៊ី ដោយសង្ស័យថាបានបំពានច្បាប់ឥណ្ឌូណេស៊ី ។ ចំណែកឯនៅប្រទេសកម្ពុជាវិញ បណ្តឹងមួយចំនួនត្រូវបានធ្វើឡើងប្រឆាំងនឹងម្ចាស់នាវា អ្នកគ្រប់គ្រង ប្រធានក្រុម និងបក្សពួក ពាក់ព័ន្ធនឹងបទល្មើស

មួយចំនួនក្រោមច្បាប់កម្ពុជា ហើយបណ្តឹងទាំងនេះកំពុងតែត្រូវបានតុលាការមានសមត្ថកិច្ចចាត់ការតាមនីតិវិធីច្បាប់ ។

រាជរដ្ឋាភិបាលកម្ពុជា បានស្នើសុំជំនួយពី រដ្ឋាភិបាលឥណ្ឌូណេស៊ី ដើម្បីនាំខ្លួនជនល្មើស និង បក្សពួករបស់គេ មកផ្តន្ទាទោស និង ដើម្បីយកប្រេងឆៅកម្ពុជាមកវិញ ស្របតាមច្បាប់ជាតិរបស់ប្រទេសទាំងពីរ និង ច្បាប់អន្តរជាតិផងដែរ ។

រាជរដ្ឋាភិបាលកម្ពុជា ក៏សូមថ្លែងអំណរគុណដល់ រដ្ឋាភិបាលឥណ្ឌូណេស៊ី សម្រាប់ការសហការនាពេលកន្លងមក រហូតដល់បច្ចុប្បន្ន ។

**ក្រសួងរ៉ែនិងថាមពល** បានទទួលដំណឹងថា បច្ចុប្បន្ននាវិកទាំងអស់ត្រូវបានឃាត់ខ្លួនដើម្បីស៊ើបអង្កេតលើករណីពាក់ព័ន្ធនឹងបទល្មើស ឬត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងបទល្មើសដែលប្រព្រឹត្តិនៅក្នុងប្រទេសកម្ពុជា និង ប្រទេសឥណ្ឌូណេស៊ី។ បញ្ហានេះ គឺជានីតិវិធី ផ្លូវច្បាប់សុទ្ធសាធ ហើយមិនពាក់ព័ន្ធនឹងបញ្ហានយោបាយ ឬ ពាណិជ្ជកម្មឡើយ ។

## សកម្មភាពបន្ទាប់

ក្នុងនាមជាម្ចាស់នៃប្រេងឆៅ **រាជរដ្ឋាភិបាលកម្ពុជា** បាននិងបន្តចាត់វិធានការផ្សេងៗទៀតដែលចាំបាច់ ដើម្បីយកប្រេងឆៅមកវិញ និងដើម្បីធានាថាច្បាប់ត្រូវបានអនុវត្តដោយត្រឹមត្រូវ និងពេញលេញ។

ដោយសារបញ្ហានេះ កំពុងតែស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេត **ក្រសួងរ៉ែនិងថាមពល** សូមមិនធ្វើការអត្ថាធិប្បាយអ្វីផ្សេងបន្ថែមទៀតទេ។

អាស្រ័យហេតុនេះ សូមសាធារណជន អ្នកសារព័ត៌មានជាតិនិងអន្តរជាតិជ្រាបជាព័ត៌មាន។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

ក្រសួងរ៉ែ និងថាមពល
**Ministry of Mines and Energy**
លេខ: 1836 MME

......03.., September, 2021

**MEDIA STATEMENT**

## STATEMENT RELATING TO MT STROVOLOS AND THE CARGO OF THE KINGDOM OF CAMBODIA

This statement is issued by the Ministry of Mines and Energy in relation with the vessel MT STROVOLOS and the cargo on board of approximately 300,000 bbls of crude oil belonging to the Kingdom of Cambodia.

### Executive summary

The purpose of this statement is to make it clear that:

- The cargo of crude oil on the MT STROVOLOS belongs to the Kingdom of Cambodia;
- The disputes regarding the payment of hire are between the vessel's owners/managers and the charterer and do not involve the Kingdom of Cambodia;
- MT STROVOLOS illegally left Cambodian waters and took steps to evade detection once it had done so, eventually entering Indonesian waters where it has been detained; and
- Consequently, various breaches of Cambodian and Indonesian laws have been committed and are now the subject of investigation and legal process.

### Background

WTM are the managers of MT STROVOLOS which was employed by a company belonging to the KrisEnergy Group to act as a floating storage and offloading (FSO) in the Apsara Block A, offshore Cambodia (Cambodia Block A). The vessel was under charter to KrisEnergy to perform that service, which had an agreement with the Royal Government of Cambodia, as represented by the Ministry of Mines and Energy, for the exploration and development in the Cambodia Block A .

### Removal of the cargo from Cambodian waters

The vessel was moored and connected to the production barge INGENIUM II to receive crude oil from it, to perform its service as an FSO and permit offtake onto other vssels, subject to local laws and regulations.The Ministry of Mines and Energy understands that there are ongoing claims between the owners/managers of the vessel and KrisEnergy regarding, among others, the payment of the hire of the vessel. If this is indeed the situation,



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

then it is a matter between them and has nothing to do with the Royal Government of Cambodia and its crude oil.

Whilst under charter to KrisEnergy, the vessel master was instructed by WTM in the evening of 18 June 2021 to depart Cambodia at 8p.m. to Thai waters with the cargo of crude oil. The departure of the vessel was without obtaining customs clearance or permission from the Cambodian authorities, and in breach of Cambodian laws.

The automatic identification system (AIS) of the vessel went offline at 12:23 a.m. on 19 June 2021 which made the vessel undetectable and went back online at 10:48 p.m. on 20 June 2021, almost 2 days later after the vessel had left Cambodian waters. Her AIS continued to be offline from time to time during her subsequent journey to Indonesian waters.

The Ministry of Mines and Energy rejects the assertion by WTM in its media statement that the vessel had no realistic choice but to sail the vessel out of Cambodian waters to undertake crew change and bunkering. At no time were the Ministry of Mines and Energy or the Cambodian authorities contacted by the vessel owners, the managers or any other party to arrange or permit any crew change or the bunkering of the vessel. In any event, neither of these matters would excuse the removal of the vessel and cargo of crude oil from Cambodian waters in breach of Cambodian laws. Since her unlawful departure, the vessel has made no attempt to return to Cambodian waters nor has she taken any steps to return the cargo of crude oil. This is despite the vessel owners, managers, master and officers being fully aware that the crude oil belongs to the Kingdom of Cambodia.

**Present position**

The Ministry of Mines and Energy understands that the vessel is currently being detained in the Republic of Indonesia for potential breaches of Indonesian laws. In Cambodia, Criminal complaints have been filed against the vessel owners, managers, the master, the chief officer and their accomplices for various criminal offences under Cambodian law. Those complaints are being dealt with by the competent Cambodian courts.

The Royal Government of Cambodia has sought the assistance of the Indonesian Government to bring the perpetrators and their accomplices to justice and to obtain the restoration of the cargo of crude oil to the Kingdom of Cambodia according to international laws and domestic laws of the two respective countries.

The Royal Government of Cambodia is grateful to the Indonesian Government for its cooperation to date in that regard.

The Ministry of Mines and Energy understands that the crew presently are being arrested and investigated for, or having been charged with committing offences in Indonesia and Cambodia. Those matters will have to take their legal course and they are neither political nor commercial matters.

**Way forward**

As the owner of the cargo of crude oil, the Royal Government of Cambodia has taken, and will continue to take, all necessary steps to recover the crude oil and ensure the due enforcement of law.

As matters are ongoing and subject to legal process, the Ministry of Mines and Energy does not intend to make further comments at this time.

As illustrated above, please be informed on the above matters.